គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

លេខ:៥៩៣/០៥២៤/សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤

# សេចក្ដីសម្រេច
# ស្ដីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈទាក់ទងការបរទេស នៃគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា

- យោងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស
- សេចក្ដីកំណត់លេខ៤០ សណ.គក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្ដីពីតួនាទី សិទ្ធិអំណាច និងអង្គការចាត់តាំងរបស់គណៈទាក់ទងបរទេស
- សេចក្ដីណែនាំបន្ថែមលេខ១៣០ សណ.គក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបន្ថែមរចនាសម្ពន្ធ័អង្គការចាត់តាំងរបស់គណៈទាក់ទងបរទេស
- យោងសភាពការណ៍ និងសំណូមពរការងារនាដំណាក់កាលបច្ចុប្បន្ន
- យោងតាមស្មារតីសម្រេចរបស់អង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាល នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

សេចក្ដីសម្រេចនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា។

## ជំពូកទី២
## តួនាទី មុខងារ ភារកិច្ច និងសិទ្ធិអំណាច

**ប្រការ២ ._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្ដាល មានតួនាទីជាសេនាធិការឱ្យគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលលើនយោបាយការបរទេស និងសហប្រតិបត្តិការអន្តរជាតិរបស់គណបក្ស។

**ប្រការ៣ ._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្ដាល មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- តាមដានសភាពការណ៍ ស្រាវជ្រាវ និងវិភាគព័ត៌មានក្នុងនិងក្រៅប្រទេស ដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់កម្ពុជា
- រៀបចំគោលនយោបាយការបរទេស និងលើកយោបល់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលពិនិត្យសម្រេច
- រៀបចំផែនការសកម្មភាព តាមដានការអនុវត្ត និងការពារគោលនយោបាយការបរទេសរបស់គណបក្ស
- ទំនាក់ទំនងជាមួយអង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ ស្ថាប័នពាក់ព័ន្ធ និងក្រុមសិក្សាស្រាវជ្រាវ ដើម្បីប្រមូលទិន្នន័យនានា សម្រាប់ការបម្រើការងារគោលនយោបាយការបរទេសរបស់គណបក្ស
- រៀបចំគោលការណ៍ និងកម្មវិធីនៃការផ្លាស់ប្ដូរទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយគណបក្សនៃបណ្ដាប្រទេសលើសកលលោក ដើម្បីដាក់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលពិនិត្យសម្រេច
- ពង្រឹង និងពង្រីកទំនាក់ទំនងរវាងគណបក្សប្រជាជនកម្ពុជាជាមួយបណ្ដាអង្គការ អន្តរគណបក្ស អង្គការតំបន់ និងអន្តរជាតិនានា
- ចូលរួម និងរៀបចំកិច្ចប្រជុំថ្នាក់អនុតំបន់ តំបន់ និងពិភពលោក ពាក់ព័ន្ធនឹងកិច្ចការបរទេស តាមការចាត់តាំងរបស់គណបក្ស
- សម្របសម្រួល និងរៀបចំទស្សនកិច្ចរបស់គណៈប្រតិភូគណបក្សនៅបរទេស និងទទួលគណៈប្រតិភូបរទេស ដែលមកបំពេញបេសកកម្ម ឬទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា តាមរយៈគណបក្ស
- គ្រប់គ្រងមន្ត្រីដែលបម្រើការងារនៅក្នុងអង្គភាពនៃគណៈទាក់ទងការបរទេស និងរៀបចំបណ្ដុះបណ្ដាលមុខជំនាញដែលពាក់ព័ន្ធនឹងកិច្ចការបរទេសនានា
- ទំនាក់ទំនងជាមួយបណ្ដាគណៈកម្មាធិការគណបក្ស សាខាបក្សនានា របស់គណបក្សប្រជាជនកម្ពុជាប្រចាំនៅបរទេស។

## ជំពូកទី៣

## ថ្នាក់ដឹកនាំ និងរបៀបរបបការងារ

**ប្រការ៤._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្ដាលដឹកនាំដោយប្រធាន ១រូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

**ប្រការ៥._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្ដាលអនុវត្តការងារតាមរបបប្រធាន។

## ជំពូកទី៤
## រចនាសម្ព័ន្ធ

**ប្រការ៦._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្តាលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១. មន្ទីរ

២. នាយកដ្ឋាន អាស៊ី-ប៉ាស៊ីហ្វិក

២. នាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

៣. នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអង្គការអន្តរគណបក្ស

៤. នាយកដ្ឋានស្រាវជ្រាវ វិភាគ និងព្យាករណ៍

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្តាលអាចបង្កើតអង្គភាពចំណុះ តាមការចាំបាច់ ដោយមានការយល់ព្រមពីគណៈប្រចាំការនៃគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។ អង្គការលេខ គណៈទាក់ទងការបរទេស នៃគណៈកម្មាធិការកណ្តាល ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ៧._**

មុខងារ និងភារកិច្ចរបស់អង្គភាពចំណុះ ត្រូវកំណត់ដោយសេចក្តីកំណត់របស់ប្រធាន គណៈទាក់ទងការបរទេស។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៨._**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩._**

គណៈទាក់ទងការបរទេសនៃគណៈកម្មាធិការកណ្តាល និងស្ថាប័នពាក់ព័ន្ធនានាជុំវិញ គណៈកម្មាធិការកណ្តាល ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ហ៊ុន សែន